## ខ្លឹមសារដកស្រង់សាលក្រមឬសាលដីកាតុលាការកម្ពុជា

## គោលការណ៍នីត្យានុកូល

...យល់ឃើញថា ជនត្រូវចោទ ឈ្មោះ ...**កញ្ញា** បានបរិហាកេរ្តិ៍លើឈ្មោះ...**ទូច** ដោយនិយាយថា មីផិតប្តី ដែលអំពើនេះជាបទបរិហាកេរ្តិ៍ បទព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៦៣នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

....យល់ឃើញថា តាមមាត្រា៦៣ថ្មីនៃច្បាប់ស្តីពីវិសោធនកម្មមាត្រា៦៣នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលនិងមាត្រានៃក្រមព្រហ្មទណ្ឌកម្មមានលក្ខណៈជាពិន័យ ដែលស្រាលជាងទោសគុក។ ដូចនេះគប្បីតុលាការកំពូលអនុវត្តតាមមាត្រា១០នៃក្រមព្រហ្មទណ្ឌ។

យល់ឃើញថាសាលដីកាព្រហ្មទណ្ឌលេខ៧៣ស ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ លើកលែងតែទណ្ឌកម្មដែលសម្រេចលើឈ្មោះ..**កញ្ញា** ដែលត្រូវញែកឲ្យដាច់ពីគ្នាលើបទបង្ករបួសស្នាមនិងបរិហាកេរ្តិ៍។

(សាលដីកាតុលាការកំពូលលេខ២៣ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៣, ទំ.៤និង៥)

*មាត្រា ១០ ការអនុវត្តច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង ឬធ្ងន់ជាង ៖ បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសដែលស្រាលជាងត្រូវអនុវត្តភ្លាម ។ ប៉ុន្តែការផ្តន្ទាទោសដែលជាស្ថាពរហើយនោះត្រូវអនុវត្ត ទោះបីទោសដែលប្រកាសនោះធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ។ បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសធ្ងន់ជាង នឹងត្រូវអនុវត្តតែទៅលើអំពើដែលបានប្រព្រឹត្តក្រោយការចូលជាធរមាននៃបទប្បញ្ញត្តិនោះ ។*